**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ៧៤ "ម"
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២
សំណុំរឿងព្រហ្មទណ្ឌលេខ៣២៤៨
ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ៥២៧២
ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ៤០១៨
ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

## **តាងនាមប្រជារាស្ត្រខ្មែរ**
## **សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម:

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៣២៤៨ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] **សុធី** ហៅ **ស្រស់** ភេទស្រី អាយុ ៣៤ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរប្រធានក្រុមហ៊ុន កម្រិតវប្បធម៌បរិញ្ញាបត្ររងអក្សរសាស្ត្រចិន ទីកន្លែងកំណើតនៅសង្កាត់[redacted] ភ្នំពេញ។ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ[redacted] រាជធានីភ្នំពេញ។ ប្តីឈ្មោះ [redacted] ខ្វាន់ប្ញូរ៉ាវុធ មានកូន០២នាក់ ឪពុកឈ្មោះ [redacted] ប៉ោលីន "រស់" ម្តាយឈ្មោះ [redacted] ហៀង "រស់" ជានីតិជន។ ទោសពីមុនគ្មាន។ (ក្រៅឃុំ)។

ជាប់ចោទពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] រតនៈសុវណ្ណា ភេទស្រី អាយុ ៣៥ឆ្នាំ មានទីលំនៅផ្ទះលេខ១២៦៤ (បុរីហាយសាវេន) ភូមិត្រពាំងវែចេក សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (អវត្តមាន)។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនៈសុវណ្ណា លោក [redacted] (វត្តមាន)។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុធី ហៅ ស្រស់ លោក [redacted] (វត្តមាន)។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] រតនៈសុវណ្ណា។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៥២២០ អ.យ.ខ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៣៦៣៨ អ.យ.ខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥២១៩ "ភ"ង.ង ចុះថ្ងៃ០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ:

-កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ក្រុមហ៊ុនវីឡាបិល អេឡិចត្រិច តំណាងដោយឈ្មោះ[redacted]សុធី បានទទួលការងាររត់ការរៀបចំឯកសារផ្ទេរកម្មសិទ្ធិដីធ្លី និងបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិអោយអតិថិជនដែលបានទិញដីពីក្រុមហ៊ុនយ៉ែនតាវអិនធើណេតសិនណល ដែលតំណាងដោយឈ្មោះ [redacted] សៀវវួច ចំនួន៣១ប្លង់ ដែលមានតម្លៃសេវា ២០៤,៦០០ ដុល្លារ តាមកិច្ចសន្យា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ ក្រោយពីទទួលប្រាក់គ្រប់ចំនួនហើយឈ្មោះ [redacted] សុធី បានចាត់ចែងរត់ការរៀបចំឯកសារផ្ទេរកម្មសិទ្ធិអោយទៅក្រុមហ៊ុនយ៉ែនតាវ បានចំនួនតែ២៨ប្លង់ប៉ុណ្ណោះ ចំណែកការងារដែលនៅសល់មិនទាន់បានធ្វើរួចគ្រប់ចំនួនតាមកិច្ចសន្យាមិនព្រមធ្វើបន្ត និងមិនព្រមប្រគល់ប្រាក់ដែលនៅសល់ទៅអោយក្រុមហ៊ុនយ៉ែនតាវវិញ តាមបណ្តឹងរបស់ឈ្មោះ [redacted] រតនៈសុវណ្ណា ដែលជាអ្នកទទួលសិទ្ធិពីឈ្មោះ [redacted] សៀងវួច។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]សុធី ហៅ ស្រស់ បានឆ្លើយនាពេលសវនាការថា: ខ្លួនត្រូវជាប្រធានក្រុមហ៊ុន វីឡាបិល អេឡិចត្រិច ជាក្រុមហ៊ុនទទួលសេវាកម្មរត់ការផ្ទេរកម្មសិទ្ធិដីធ្លីផ្ទះ និងបង់ពន្ធជូនរដ្ឋ។ ឈ្មោះ [redacted] ភីសៀវ បានជួលក្រុមហ៊ុនជាអ្នករត់ការផ្ទេរកម្មសិទ្ធិផ្ទះ និងរត់ការបង់ពន្ធជូនរដ្ឋ ដោយមានធ្វើកិច្ចសន្យាជាមួយគ្នាត្រឹមត្រូវ។ បន្ទាប់ពីទទួលការងារនេះឈ្មោះ [redacted] ភីសៀវ បានជួលក្រុមហ៊ុនរត់ការផ្ទេរកម្មសិទ្ធិដីផ្ទះចំនួន៣១ប្លង់ ហើយក្នុងមួយប្លង់មានតម្លៃ ៦,៦០០ ដុល្លារ។ ប៉ុន្តែ ការរត់គឺរត់ការបានតែ២៨ប្លង់ទេ។ នៅសល់៣ប្លង់ ដែលមានតម្លៃ៦,៦០០ ដុល្លារ មួយប្លង់ មិនទាន់រត់ការផ្ទេរកម្មសិទ្ធិរួចរាល់។ ក្រោយមកស្រាប់តែមានឈ្មោះ [redacted] រតនៈសុវណ្ណា បានអះអាងថាគាត់ជាម្ចាស់ក្រុមហ៊ុនជាមួយឈ្មោះ [redacted] ភីសៀវ គាត់មកទាមទារប្រាក់កក់ដែលនៅសល់ពីខាងក្រុមហ៊ុនវិញ ដោយមូលហេតុខាងក្រុមហ៊ុនគាត់ចង់រំលាយកិច្ចសន្យាជួលសេវាក្រុមហ៊ុនខ្ញុំ និងសុំទាមទារប្រាក់កក់វិញ ប៉ុន្តែ ខាងខ្ញុំបានប្រាប់គាត់ថាលុយកក់ យើងមិនអាចអោយវិញបានទេ ព្រោះយើងបានចំណាយទៅរត់ការផ្ទេរកម្មសិទ្ធិនៅខាងសុរិយោដីអោយគាត់អស់ហើយ តែខាងគាត់នៅតែទាមទារចង់បញ្ឈប់កិច្ចសន្យា និងទាមទារប្រាក់កក់ពីខាងខ្ញុំដដែល។ ដោយសារតែខាងខ្ញុំមិនព្រមរំលាយកិច្ចសន្យាទើបឈ្មោះ [redacted] រតនៈសុវណ្ណា និងមេធាវីខាងក្រុមហ៊ុនខ្ញុំឈ្មោះ [redacted] ជាបានជួបចរចារគ្នាពីរឿងទាមទារប្រាក់កក់ចំនួន ៤៦,២០០ ដុល្លារ ស្មើរនិង៧ប្លង់ តែជាក់ស្តែងប្រាក់កក់គាត់ គឺសល់តែ៣ប្លង់ទេ ស្មើនឹងទឹកប្រាក់១៩,៨០០ ដុល្លារ ប៉ុណ្ណោះ។ ដោយការចរចារមិនអាចទៅរួច ព្រោះខាងក្រុមហ៊ុនខ្ញុំមិនអាចរំលាយកិច្ចសន្យាជាមួយគាត់ ដោយគ្មានមូលហេតុត្រឹមត្រូវ ទើបខាងឈ្មោះ [redacted] រតនៈសុវណ្ណា ប្តឹងខាងខ្ញុំដូចនេះ។ ដែលការប្តឹងនេះ គឺជារឿងមិនត្រឹមត្រូវទេ ព្រោះរឿងនេះជារឿងរដ្ឋប្បវេណីទាក់ទងនឹងកិច្ចសន្យាប៉ុណ្ណោះ ហើយម្យ៉ាងទៀតខាងខ្ញុំនៅតែបំពេញកាតព្វកិច្ចផ្ទេរកម្មសិទ្ធិអោយគាត់ដដែល អោយតែគាត់ប្រគល់ឈ្មោះអ្នកទិញមកអោយខាងក្រុមហ៊ុនខ្លួន។ ហើយឈ្មោះ [redacted] រតនៈសុវណ្ណា មិនមែនជាម្ចាស់ក្រុមហ៊ុន និងមិនមានលិខិតផ្ទេរកម្មសិទ្ធិអោយប្តឹងខ្លួនឡើយ។

-ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ [redacted] រតនៈសុវណ្ណា ចុះថ្ងៃ១៤ ខែធ្នូ ឆ្នាំ២០២០ នៅដំណាក់កាលចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]រតនៈសុវណ្ណា លោក [redacted]ត្រា បានធ្វើសេចក្តីសន្និដ្ឋានការពារថា: យោងតាមអង្គហេតុ និងអង្គច្បាប់ខាងលើ សបញ្ជាក់អោយឃើញថាឈ្មោះ [redacted]សុធី ដែលជាម្ចាស់ក្រុមហ៊ុនវីឡាបិល អេឡិចទិច និងឈ្មោះ [redacted] ហេងទ្រី ដែលជាអ្នកតំណាង និងបុគ្គលិកក្រុមហ៊ុន ពិតជាមានចេតនាទុច្ចរិតក្នុងការ



Scanned with CamScanner

តែបំបាត់មូលនិធិ ដែលជាប្រាក់កក់ ដែលកូនក្តីខ្ញុំបាទបានប្រគល់អោយទុកប្រើប្រាស់ជាកំណត់សម្រាប់តែការរត់ការកាត់ឈ្មោះ ប្លង់ផ្ទះតែប៉ុណ្ណោះ។ ប៉ុន្តែ មិនទាន់បានកាត់ប្លង់រួចរាល់ផងបែរជាឈ្មោះ [redacted] សុធី និងឈ្មោះ [redacted] ហេងទ្រី រួមគំនិតគ្នាយកប្រាក់ទាំងនោះទៅប្រើប្រាស់ក្នុងកម្មវត្ថុផ្សេងទៅវិញ។ ទន្ទឹមនឹងនេះផងដែរ ទោះបីជាក្រុមហ៊ុនម្ចាស់គម្រោងស្នើសុំប្រគល់មកវិញយ៉ាងណាក៏ ដោយក៏ឈ្មោះ [redacted] សុធី ឈ្មោះ [redacted] ហេងទ្រី និងបក្ខពួកខ្លួន នៅតែប្រកាន់គំនិតទុច្ចរិតគេចវេសមិនព្រមប្រគល់ប្រាក់កក់មកវិញដែរ។

ផ្អែកលើសកម្មភាពទុច្ចរិតរបស់ឈ្មោះ [redacted] សុធី ដែលជាម្ចាស់ក្រុមហ៊ុន វីឡូបិល អេឡិចទិច ឈ្មោះ [redacted] ហេងទ្រី និងបក្ខពួក ដែលបានប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ គឺសបញ្ជាក់យ៉ាងច្បាស់អំពីតែបំបាត់ទ្រព្យសម្បត្តិ ដែលឈ្មោះ [redacted] សុធី ឈ្មោះ [redacted] ហេងទ្រី និងបក្ខពួករបស់ខ្លួន បានទទួលពីក្រុមហ៊ុនម្ចាស់គម្រោង ដែលមានកូនក្តីខ្ញុំបាទជាអ្នកតំណាង ដើម្បីយកមកប្រើប្រាស់ជាកំណត់ក្នុងការកាត់ប្លង់ផ្ទេរកម្មសិទ្ធិលើផ្ទះ។ ក៏ប៉ុន្តែ ខ្លួនបែរជាគេចវេសចំពោះភារកិច្ចរបស់ខ្លួនដោយមិនធ្វើការរត់កាត់ប្លង់អោយបានសម្រេច និងមិនព្រមប្រគល់ប្រាក់សេសសល់ដែលកើតចេញពីការមិនសម្រេចបាននូវការងាររបស់ខ្លួននោះ មកអោយកូនក្តីខ្ញុំបាទ ក្នុងនាមជាអ្នកតំណាងរបស់ក្រុមហ៊ុនម្ចាស់គម្រោងទៅវិញ។ អំពើទាំងនេះ គឺជាអំពើដែលត្រូវបានផ្តន្ទាទោសពីបទៈ រំលោភលើទំនុកចិត្ត ពិតប្រាកដមែន តាមរយៈក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ ក្រោយពីបានដេញដោយក្នុងពេលសវនាការនាពេលនេះ ឃើញថាៈជនជាប់ចោទឈ្មោះ [redacted] សុធី ហៅ ស្រស់ បានទទួលរត់ការប្លង់ផ្ទះចំនួន៣១ប្លង់ស្មើនឹងទឹកប្រាក់ចំនួន៤០០,០០០ ដុល្លារ ក្រោយពីទទួលប្រាក់បានមួយចំនួនហើយ ពេលដែលរត់ការធ្វើប្លង់ គឺបានរត់ការបានតែចំនួន២៨ប្លង់តែប៉ុណ្ណោះ។ ហើយក៏មិនរត់ការបន្តទៀតទេ ហើយក៏មិនបានប្រគល់ទៅអោយគេវិញដែរ។ បើយើងពិនិត្យនៅក្នុងរឿងនេះ គឺជាចូលទៅរឿងកិច្ចសន្យា ដូនេះតាមការណែនាំរបស់ក្រសួងយុត្តិធម៌។ ដូចនេះតំណាងអយ្យការស្នើសុំអោយតុលាការពិចារណា និងធ្វើការសម្រេចទៅតាមផ្លូវច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុធី ហៅ ស្រស់ លោក [redacted] សុវណ្ណឌី បានធ្វើសេចក្តីសន្និដ្ឋានការពារថាៈ ក្រោយពីបានសាកសួរដេញដោលគ្រប់ភាគីនាពេលសវនាការរួចពិនិត្យលើអង្គហេតុ អង្គច្បាប់ និងភស្តុតាង យើងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យកូនក្តីឈ្មោះ [redacted] សុធី សូមធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិដូចតទៅៈឃើញថានៅក្នុងសំណុំរឿងនេះអ្នកប្តឹងឈ្មោះ [redacted] រតនៈសុវណ្ណា ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមជានីតិបុគ្គល ឬក្រុមហ៊ុន យ៉ងតាវ អិនធើណេសិនណល តំណាងដោយឈ្មោះ [redacted] ភីស៊ីវ ពីព្រោះសំណុំរឿងគ្មានលិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនច្បាប់ដើម។ ឃើញថាលិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ [redacted] ភីស៊ីវ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានបញ្ជាក់ថាៈ ខ្លួន ប្រគល់សិទ្ធិសម្រេចការងារតំណាងម្ចាស់គម្រោង ទទួលខុសត្រូវលើការងារទូទៅក្នុងគម្រោងសាងសង់ផ្ទះល្វែងចំនួន៤០ ល្វែង ទាំងមូលជូនលោកស្រី [redacted] រតនៈសុវណ្ណា ។ ប៉ុន្តែពុំមានការប្រគល់សិទ្ធិឱ្យធ្វើជាតំណាងក្រុមហ៊ុនក្នុងការប្តឹងកូនក្តីខ្ញុំពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិផ្ទះល្វែងចំនួន៣១ ល្វែងឡើយ។ ឃើញថាកិច្ចសន្យា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ បានបញ្ជាក់ថាៈក្រុមហ៊ុន យ៉ងតាវ អិនធើណេសិនណល និងក្រុមហ៊ុនកូនក្តីយើងខ្ញុំមានទំនាក់ទំនងគតិយុត្តអនុវត្តកិច្ចសន្យាត្រូវបំពេញកាតព្វកិច្ចរៀងៗខ្លួនក្នុងការផ្តល់សេវាការងាររៀបចំឯកសារផ្ទេរកម្មសិទ្ធិដីធ្លី និងបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ។ ហើយប្រាក់កក់ដែលកូនក្តីយើងខ្ញុំបានទទួលពីក្រុមហ៊ុន យ៉ងតាវ អិនធើណេសិនណល គឺជាប្រាក់ធានាកាតព្វកិច្ចអនុវត្តកិច្ចសន្យា។ ឃើញថាចម្លើយដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថាៈ ក្រុមហ៊ុន យ៉ងតាវ អិនធើណេសិន

ណល មានបញ្ហាផ្ទៃក្នុង និងចង់រំលាយកិច្ចសន្យាដោយឯកតោភាគី ហើយទាមទារប្រាក់កក់ត្រឡប់ទៅវិញ នេះជាភស្តុតាងបញ្ជាក់អំពីអង្គហេតុកិច្ចសន្យា ដោយភាគីម្ខាងមិនបានបំពេញកាតព្វកិច្ចត្រឹមត្រូវតាមច្បាប់ និងមិនមែនជាកំហុសរបស់កូនក្ដីខ្ញុំនោះទេ។ ផ្អែកតាមទាំងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយរបស់កូនក្ដីខ្ញុំ ចម្លើយរបស់សាក្សី និងភស្តុតាងជាឯកសារនានាពាក់ព័ន្ធឃើញថាជាអង្គហេតុដែលពាក់ព័ន្ធទៅនឹងវិវាទ ដែលកើតចេញពីការអនុវត្តកាតព្វកិច្ចកិច្ចសន្យាមួយរវាងក្រុមហ៊ុន យ៉េនតាវ អិនធើណេសិនណល និងក្រុមហ៊ុនកូនក្ដីខ្ញុំ ជារឿងវិវាទរដ្ឋប្បវេណីសុទ្ធសាធ ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ។ ផ្អែកតាមអង្គហេតុ និងទិដ្ឋភាពច្បាប់ ឃើញថា មានភាពស៊ីសង្វាក់ជាមួយនឹងភស្តុតាងខាងលើបញ្ជាក់ថាកូនក្ដីខ្ញុំមិនបានប្រព្រឹត្តបទល្មើសដូចការប្ដឹងចោទនោះទេ គឺជាករណី វិមតិសង្ស័យ។ ឃើញថាធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ក្នុងការដាក់បន្ទុកមកលើកូនក្ដីខ្ញុំពីបទ រំលោភលើទំនុកចិត្ត នោះទេ។ ផ្អែកតាមមាត្រា៣៨ កថាខណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងបញ្ញត្តិមាត្រា៣៥១ នៃក្រម នីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។ ផ្អែកតាមមាត្រា៣៥០ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌចែងថា៖ ប្រសិនបើតុលាការយល់ឃើញថាអំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ។

-ជនជាប់ចោទឈ្មោះ[redacted]សុធី ហៅ ស្រស់ និយាយសំដីចុងក្រោយថា៖សុំតុលាការជួយអោយខ្លួនបានរួចផុតបទចោទ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្ដាប់ការអានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ក្រោយពីបានស្ដាប់សំដីចុងក្រោយជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

១-ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥២១៩ "ភ"ង.ង ចុះថ្ងៃ០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនឈ្មោះ [redacted] សុធី ហៅ ស្រស់ ភេទស្រី អាយុ ៣៤ឆ្នាំ ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] សុធី ហៅ ស្រស់ បានឆ្លើយបញ្ជាក់ថា: ខ្លួនត្រូវជាប្រធានក្រុមហ៊ុន វីឡែប៊ីល អេឡិចត្រិច ជាក្រុមហ៊ុនទទួលសេវាកម្មរត់ការផ្ទេរកម្មសិទ្ធិដីផ្ទះ និងបង់ពន្ធជូនរដ្ឋ។ ឈ្មោះ [redacted] ភីសៀវ បានជួលក្រុមហ៊ុនជាអ្នករត់ការផ្ទេរកម្មសិទ្ធិផ្ទះ និងរត់ការបង់ពន្ធជូនរដ្ឋ ដោយមានធ្វើកិច្ចសន្យាជាមួយគ្នាត្រឹមត្រូវ។ បន្ទាប់ពីទទួល ការងារនេះឈ្មោះ [redacted] ភីសៀវ បានជួលក្រុមហ៊ុនរត់ការផ្ទេរកម្មសិទ្ធិដីផ្ទះចំនួន៣១ប្លង់ ហើយក្នុងមួយប្លង់មានតម្លៃ៦,៦០០ ដុល្លារ។ ប៉ុន្តែ ការរត់តឹងរត់ការបានតែ២៨ប្លង់ទេ។ នៅសល់៣ប្លង់ ដែលមានតម្លៃ៦,៦០០ ដុល្លារ មួយប្លង់ មិនទាន់រត់ការផ្ទេរកម្មសិទ្ធិរួចរាល់។ ក្រោយមកស្រាប់តែមានឈ្មោះ [redacted] រតនៈសុវណ្ណា បានអះអាងថាគាត់ជាម្ចាស់ក្រុមហ៊ុនជាមួយឈ្មោះ [redacted] ភីសៀវ គាត់មកទាមទារប្រាក់កក់ដែលនៅសល់ពីខាងក្រុមហ៊ុនវិញ ដោយមូលហេតុខាងក្រុមហ៊ុនគាត់ចង់រំលាយ



Scanned with CamScanner

កិច្ចសន្យាជួលសេវាក្រុមហ៊ុនខ្ញុំ និងសុំទាមទារប្រាក់កក់វិញ ប៉ុន្តែ ខាងខ្ញុំបានប្រាប់គាត់ថាលុយកក់ យើងមិនអាចអោយវិញបានទេ ព្រោះយើងបានចំណាយទៅរត់ការផ្ទេរកម្មសិទ្ធិនៅខាងសុរិយោដីអោយគាត់អស់ហើយ តែខាងគាត់នៅតែទាមទារចង់បញ្ឈប់កិច្ចសន្យា និងទាមទារប្រាក់កក់ពីខាងខ្ញុំដដែល។ ដោយសារតែខាងខ្ញុំមិនព្រមរំលាយកិច្ចសន្យាទើបឈ្មោះ [redacted] រតនៈសុវណ្ណា និងមេធាវីខាងក្រុមហ៊ុនខ្ញុំឈ្មោះ [redacted] ជាបានជួបចរចារគ្នាពីរឿងទាមទារប្រាក់កក់ចំនួន៤៦,២០០ ដុល្លារ ស្មើរនិង៧ប្លង់ តែជាក់ស្តែងប្រាក់កក់គាត់ គឺសល់តែ៣ប្លង់ទេ ស្មើនឹងទឹកប្រាក់១៩,៨០០ ដុល្លារ ប៉ុណ្ណោះ។ ដោយការចរចារមិនអាចទៅរួច ព្រោះខាងក្រុមហ៊ុនខ្ញុំមិនអាចរំលាយកិច្ចសន្យាជាមួយគាត់ ដោយគ្មានមូលហេតុត្រឹមត្រូវ ទើបខាងឈ្មោះ [redacted] រតនៈសុវណ្ណា ប្តឹងខាងខ្ញុំដូចនេះ។ ដែលការប្តឹងនេះ គឺជារឿងមិនត្រឹមត្រូវទេ ព្រោះរឿងនេះជារឿងរដ្ឋប្បវេណីទាក់ទងនឹងកិច្ចសន្យាប៉ុណ្ណោះ ហើយម្យ៉ាងទៀតនាងខ្ញុំនៅតែបំពេញកាតព្វកិច្ចផ្ទេរកម្មសិទ្ធិអោយគាត់ដដែល អោយតែ គាត់ប្រគល់ឈ្មោះអ្នកទិញមកអោយខាងក្រុមហ៊ុនខ្លួន។ ហើយឈ្មោះ [redacted] រតនៈសុវណ្ណា មិនមែនជាម្ចាស់ក្រុមហ៊ុន និងមិនមានលិខិតផ្ទេរកម្មសិទ្ធិអោយប្តឹងខ្លួនឡើយ។ ដូច្នេះ តាមការអង្គហេតុ និងការពិនិត្យភស្តុតាងនានាបញ្ជាក់ថា:សំណុំរឿងព្រហ្មទណ្ឌខាងលើនេះ គឺពុំមានពិរុទ្ធភាពចំពោះបទល្មើសព្រហ្មទណ្ឌឡើយ ពីព្រោះថាសំណុំរឿងនេះ គឺជាវិវាទទាក់ទងខាងផ្នែករដ្ឋប្បវេណី។ គប្បី តុលាការបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៣២៤៨ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ ទៅជារឿងក្តីរដ្ឋប្បវេណី វិញ។

៣-ចម្លើយជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានាពុំមានភាពពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌលើជនជាប់ចោទឈ្មោះ [redacted] សុធី ហៅ ស្រស់ ភេទស្រី អាយុ ៣៩ឆ្នាំ ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ឡើយ។

៤-ពុំមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុធី ហៅ ស្រស់ ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឡើយ។ គប្បី តុលាការសម្រេចឲ្យជនជាប់ចោទរួចខ្លួនពីបទចោទតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ឲ្យឈ្មោះ [redacted] **សុធី** ហៅ **ស្រស់** ភេទស្រី អាយុ ៣៩ឆ្នាំ រួចខ្លួនពីបទចោទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុធី** ហៅ **ស្រស់** និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **រតនៈសុវណ្ណា**។ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក,ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner